# ការរកមេធាវី



**នៅ**សហរដ្ឋអាមេរិក មានក្រសួងយុត្តិធម៌ ដែលមានមេធាវីជាច្រើនធ្វើការឯកជន ហើយមានភាគតិចដែលធ្វើការក្នុង ក្រសួងដែលមិនដើម្បីរកប្រាក់ចំណេញ (Non-Profit ) ឬធ្វើការជាមេធាវីជួយដល់ពលរដ្ឋ ដែលមានប្រាក់ចំរិកាតិចឬអ្នកក្រ។ ការស្វែងរកមេធាវី គ្រប់ផ្នែកផ្លូវច្បាប់ជាការមួយពិបាក ចំពោះជនអន្តោប្រវេសន៏ ដែលជាអ្នកខ្វះខាត :

ក ) ការយល់ដឹងពីរបៀបស្មុគស្មាញ នៃច្បាប់យុត្តិធម៌របស់សង្គមថ្មី

ខ ) រស់នៅក្នុងប្រទេសថ្មី ដែលប្លែកពីប្រទេសកំណើត

គ ) ការរៀនសូត្រភាសាថ្មី។

ខាងក្រោមនេះជាយោបល់ខ្លះៗ ដើម្បីបង្ហាញផ្លូវរកមេធាវីដែលធ្វើការដោយឥតគិតថ្លៃ ឬ គេយកកំរៃតិច ។

## បើខ្ញុំជាជនមានចំណូលតិច ហើយគ្មានប្រាក់កាសណាផ្សេងទៀតជួយ តើខ្ញុំអាចរកមេធាវីណាជួយ ដោយឥតគិតថ្លៃបានទេ ?

**មា**នសបាគមន៏ត្រឹមត្រូវតាមច្បាប់ រាយខាងក្រោមនេះអាចជួយអ្នកបាន តាមតែករណីយរបស់អ្នក ដែលត្រូវការផ្នែកណានៃរឿងរ៉ាវដែលអ្នកចង់ឲ្យជួយនោះ។ តាមធម្មតាក្រសួងខាងក្រោមនេះជួយអ្នកបានដោយឥតគិតថ្លៃ។ តាមផ្នែករបស់ច្បាប់ខ្លះ ដែលសបាគមន៏នោះ មានអ្នកជួយដូចជា :

- អន្តោប្រវេសន៏
- ការចូលសញ្ជាតិ
- ការរកការងារធ្វើ
- ម្ចាស់ផ្ទះជួល / អ្នកជួលផ្ទះ
- ផលប្រយោជន៏សាធារណះ
- អំពើហឹង្សាឃោរឃៅតាមផ្ទះ និង ផ្នែកផ្សេងៗទៀត។

ចូរមើលតាមបញ្ជី ផ្នែកណាមួយរបស់ច្បាប់ ដែលលោកអ្នកអាចទទួលបានតាមការតម្រូវ។

## បើខ្ញុំជាជនមានប្រាក់ខែតិច ហើយត្រូវការអ្នកជួយខាងផ្នែកបទឧក្រឹដ្ឋ ?

បើអ្នកជាជនមានប្រាក់ចំណូលតិចមែន ហើយមានបញ្ហាខ្លះក្នុងផ្លូវច្បាប់អំពីប្រព្រឹត្តបទឧក្រឹដ្ឋ អ្នកអាចទទួលជំនួយបាន ពីក្រសួងសាធារណះតំណាងដោះសារ ( Public Defenders Office ) ចូរសួរដល់ចៅក្រមអ្នក ឲ្យជួយបញ្ជូនអ្នកទៅក្រសួងនោះ ក្នុងថ្ងៃទី១ ដែលឡើងតុលាការ។

## ចុះបើក្រុមធ្វើកិច្ចបំរើផ្លូវច្បាប់នោះ ឥតមានកិច្ចការដឹងធ្វើខាងច្បាប់ដែលខ្ញុំត្រូវការ ប៉ុន្តែខ្ញុំត្រូវការអ្នកជួយ ហើយខ្ញុំជាអ្នកមានប្រាក់ខែតិច ?

មានក្រុមមួយក្នុងក្រសួងសង្កាត់សាន់តាក្លារ៉ា **(Modest Mean Panel of the Santa Clara County Bar Association )** អាចជួយអ្នក បានបើសិនជាបញ្ហារកច្បាប់នោះ ស្ថិតនៅក្នុងចំណោម Bankrupcy, Consumer, បទឧក្រឹដ្ឋ គ្រួសារអន្តោប្រវេសន៏ យុវជនជំទង់ អ្នកមានផ្ទះ/អ្នកជួលផ្ទះ។ ជាមួយគ្នានេះ បើសិនជាអ្នកមានប្រាក់ចំណូល តាមកំណត់របស់គេ អ្នកអាចទទួលយកមេធាវីម្នាក់ ដែលគេគិតថ្លៃតែ $២៥ ក្នុងកន្លះម៉ោង ដើម្បីធ្វើការពិភាគ។ ប៉ុន្តែបើបញ្ហារបស់អ្នកធ្ងន់ធ្ងរ ហើយ ត្រូវការអ្នកជួយខាងច្បាប់ជ្រៅទៅទៀត អ្នកត្រូវតែយកមេធាវិ ដែលគេគិតឈ្នួល ហើយគេនឹងគិតថ្លៃគួរសម តាមដែលក្រសួង Modest Mean Panel តម្រូវឲ្យ។

## តើដូចម្តេច បើខ្ញុំមានប្រាក់ចំណូលច្រើន ដែលក្រសួង **Modest Mean Panel** មិនអាចជួយបាន ?

អ្នកអាចទូរស័ព្ទក្រសួងធ្វើការបញ្ជូន ( Lawer Referral Service ) ឲ្យគេជួយ។ អ្នកត្រូវតែពន្យល់ឲ្យគេដឹង អំពីបញ្ហារបស់អ្នក។ បន្ទាប់មកគេត្រូវណាត់ពេលជួបកន្លះម៉ោង សំរាប់ធ្វើការពិភាគជាមួយមេធាវី

ដែលមានកាពិសោធន៏ក្នុងផ្នែកផ្លូវច្បាប់របស់អ្នកត្រូវការ។ ក្រសួងដែលធ្វើការបញ្ជូន ( Lawyer Referral Service ) គេត្រូវឲ្យអ្នកបង់ថ្លៃ $៣០ ពីកិច្ចចាត់ការរបស់ក្រសួងគេ។ មេធាវី មិនអាចយកតម្លៃអ្វីទេនៅពេលកន្លះម៉ោងដំបូង។ មេធាវីនិងខ្លួនអ្នកផ្ទាល់ ពុំអាចពិគ្រោះច្រើនជាងការធ្វើពីភាគនោះឡើយ។ ប៉ុន្តែបើអ្នកចង់បានជំនួយវែងឆ្ងាយទៀតនោះ អ្នកត្រូវតែធ្វើការពិគ្រោះ អំពីប្រាក់ឈ្នួលក្នុងពេលធ្វើការពិភាគនោះ។

**<u>AIDS Legal Services</u>**
111 E. Saint John Street, Ste. 315, San Jose 95113
Tel: (408) 293-3135

<u>ភាសា</u>: អេស្ប៉ាញ៉ូល អង់គ្លេស AT &T Language Line
<u>ការបំរើ</u>: សូមមើលខាងក្រោម។

<u>AIDS legal services and advocacy</u> – ការជួយបំរើផ្លូវច្បាប់សំរាប់អ្នកដែលមានជម្ងឺ AIDS និងរោគ HIV។
<u>Fair Housing Law Project</u>: សិទ្ធិក្នុងការរកផ្ទះនៅ។
**<u>LACY</u>**: ការឃោសនាពីច្បាប់ ការពារកូនក្មេងនិងក្មេងជំទង់ រៀនពីច្បាប់ ឲ្យសេរីភាពទៅអ្នកអន់ខ្សោយ ជួយជាអ្នករក្សាក្មេង អ្នកឥតមានទីលំនៅ និងក្មេងជំទង់ដែលរត់ចោលទីលំនៅ និងអ្នកមានផ្ទៃពោះ និងក្មេងជំទង់ដែលមានកូន។ ការបំរើខាងផ្លូវច្បាប់ និងផ្លូវសង្គម ដល់អ្នកភាគតិចដោយឥតគិតថ្លៃ។

**Asian Law Alliance**
184 East Jackson St., San Jose, CA 95112
Tel : (408) 287-9710
Website : www.asianlawalliance-ala.org.

<u>ភាសា :</u> ចិនកង់តុង លាវ ចិនម៉ាន់ដ៉ារិន វៀតណាម អេស្ប៉ាញ៉ូល។
<u>ការបំរើ:</u> សិទ្ធិពលរដ្ឋ សិទ្ធិអ្នកទិញ អំពើហឹង្សាក្នុងគ្រួសារ ការរកការងារធ្វើ ច្បាប់សំរាប់គ្រួសារ ផ្តល់ផ្ទះជួល អន្តោប្រវេសន៏ ប្រយោជន៏សាធារណះ ច្បាប់សំរាប់ចាស់ៗ។

**Bay Area Legal Aid**
2 W. Santa Clara ST., 8TH Floor, San Jose, CA 95113
tel: (408) 283-3700 X 313
Website : www.baylegal.org.

<u>ភាសា :</u> អេស្ប៉ាញ៉ូល

<u>ការបំរើ:</u> ការរីកចំរើនអាជីវកម្មនៃសង្គម អំពើហឹង្សាក្នុងគ្រួសារ កិច្ចបំរើការងារ សុខភាព ផ្តល់ផ្ទះជួល និងប្រយោជន៏សាធារណៈ។

**California Rural Legal Assistance ( Gilroy Office )**
7365 Monterey, Suite H Gilroy, CA 95020
Tel : 408 – 847-1408
Website : www.crla.org.

<u>ភាសា :</u> អេស្ប៉ាញ៉ូល
<u>ការបំរើ:</u> សិទ្ធិពលរដ្ឋ ការរីកចំរើនអាជីវកម្មនៃសង្គម ការសិក្សា ការរកការងារធ្វើ សុខភាព ផ្តល់ផ្ទះជួល ប្រយោជន៏សាធារណះ និងច្បាប់សំរាប់ចាស់ៗ។

**Eastside Community Law Center**
**Santa Clara University School of Law**
1030 The Alameda, San Jose 95126 1765
Tel: (408) 254-0444
Website : www.scu.edu./ESJCLC

<u>ភាសា :</u> អេស្ប៉ាញ៉ូល វៀតណាម និងផ្សេងៗទៀត
<u>ការបំរើ:</u> ជំនួញក្ស័យធន (Bankruptcy) ការរីកចំរើនអាជីវកម្មនៃសង្គម ជួយរកការងារឲ្យធ្វើ កិច្ចការអន្តោប្រវេសន៏ សំណងដល់អ្នកធ្វើការ។

**Legal Aid Society of Santa Clara County**
480 N. First ST., San Jose, CA 95112
Tel : (408) 998-5200
Housing Project : (408) 283-1540
Housing Discrimination : (408) 283-1535 X 237
Immigration Issues : (408) 998-5200, X 231
Website : www. Legalaidsociety.org

<u>ភាសា :</u> អេស្ប៉ាញ៉ូល
<u>ការបំរើ:</u> ជំនួយខាងច្បាប់ ដល់សង្គមនៃជនទុរគិត ក្នុងបញ្ហាពលរដ្ឋដែលមានដូចជា អំពើហឹង្សាឃោរឃៅក្នុងផ្ទះ គាំទ្រការថែរក្សាសុខភាព ច្បាប់ខាងផ្តល់ផ្ទះជួល សិទ្ធិនៃជនម្នាក់ៗ ការសម្រុះសម្រួលរវាងម្ចាស់ផ្ទះនិងអ្នកជួល កិច្ចការអន្តោប្រវេសន៏ គុណភាពនៃការ

សិក្សា និង ជំនួយកិច្ចការសិក្សាពិសេស។ មន្ទីរ Self-help ជួយញ្ហាដូចជា ការជាប់ចោទ អំពើហឹង្សាក្នុងគ្រួសារ បញ្ជាមិនឲ្យធ្វើសកម្មភាព (Restraining Order) និង ជួយសំរេចរកអ្នកណាជាឪពុក ( ជាឪពុកចិញ្ចឹម ឬគ្រាន់តែមកមើលខុសត្រូវ )។

**Pro Bono Project Sillicon Valley**
480 N. First St., Suite 219
Tel : (408) 998-5298
Websites : www.probonoproject.com

ភាសា : អេស្ប៉ាញ៉ុល
ការបំរើ: ជំនួញក្ស័យធន (Bankruptcy) សិទ្ធិអ្នកទិញ អំពើហឹង្សាក្នុងគ្រួសារ ច្បាប់សំរាប់គ្រួសារ។

**Santa Clara County Bar Association Law Foundation**
111 W. St.,John Street, Suite 315, San Jose, CA 95113
Tel : (408) 293-4790
TDD (408) 294-5667

ភាសា : អេស្ប៉ាញ៉ុល
ការបំរើ: AIDS/HIV ( អេដ៏ / អេច- អាយ - វី ) សិទ្ធិរបស់ក្មេង សិទ្ធិពលរដ្ឋ សិទ្ធិអ្នកទិញ ជនពិការ អំពើឃោរឃៅក្នុងផ្ទះ ការសិក្សា ការរកការងារធ្វើ ច្បាប់របស់គ្រួសារ សុខុមាលភាព ផ្តល់ផ្ទះជួល ប្រយោជន៏សាធារណៈ ប្រយោជន៏របស់កងទ័ពទាហានចាស់។

**Santa Clara County Bar Association Lawyer Referral Service**
4 North 2nd. Street, Room400, San Jose, CA 95113
Tel : (408) 287-2557
Tel : (408) 971- 6822 for Lawyer Referral Service
Website : www.sccbalegalink.com

ភាសា : អេស្ប៉ាញ៉ុល
ការបំរើ: ជួយបញ្ជូន អ្នកដែលត្រូវការពិភាក្សា ជាមួយមេធាវី។ ឈ្នួលកន្លះម៉ោងដំបូង តែបន្តិចបន្តួចទេ ដើម្បីណែនាំអ្នក ឲ្យជួបអ្នកស្គាល់ច្បាប់ក្នុងផ្នែកនោះ។ **Modest Mean Panel Program** ជាកម្មវិធីមួយ ដែលបំរើដល់ជនណាដែលមិនមាន សមត្ថភាពជួលមេធាវី។ ជនម្នាក់ៗត្រូវតែគេឆែកឆេរ ដល់ប្រាក់ចំណូល ដើម្បីទទួលជំនួយ។

**Senior Adults Legal Assistance (SALA)**
160 E. Virginia St., Suite 260, San Jose, CA 95112
Tel: (408) 295-5991

ភាសា : អេស្ប៉ាញ៉ុល
ការបំរើ:ធ្វើការបញ្ជូនខាងព្យាបាលសុខភាព អំពើឃោរឃៅក្នុងផ្ទះ ការធ្វើបាបមនុស្សចាស់ ក្រសួងផ្តល់ជំនួយផ្ទះជួល Medicare SSI និង បញ្ហា Social Security ប្រយោជន៏សាធារណៈជន មន្ទីររក្សាមនុស្សចាស់ ច្បាប់សំរាប់មនុស្សចាស់ៗ របៀបទុកមរតក។